សេចក្តីសង្ខេបអំពីបទសម្ភាសន៍ជាមួយ **SONNY (SONNY) CHHOUN** ទូរស័ព្ទលេខ **012 877 307** និង **096 720 5219** នៅខេត្ត សៀមរាប កាលពីថ្ងៃទី 6 ខែមីនា ឆ្នាំ 2014 ចាប់ពីម៉ោង 15:30 នាទី ដល់ម៉ោង 20:00 នាទី ទាក់ទងនឹងបញ្ហាទាំងឡាយនៅមុនពេល និងក្រោយពេលបាត់ខ្លួន DAVID **(DAVID) WALKER** នៅម៉ោងប្រហែល 14:00 នាទី ថ្ងៃទី 14 ខែកុម្ភៈ ឆ្នាំ 2014។

**SONNY** នឹង **DAVID** គឺជាមិត្តភក្តិជិតស្និទ្ធនឹងគ្នា ទាំងនៅក្នុងការងាររកស៊ី និងក្នុងសង្គម។ ពួកគេមានទំនាក់ទំនងនឹងគ្នាអស់រយៈពេលជាងមួយឆ្នាំកន្លងមកហើយ ។
(មិត្តភក្តិ និងអ្នកដទៃដែលពួកគេស្គាល់ បានកត់សម្គាល់ និងយល់ឃើញថា **SONNY** និង **DAVID** ហាក់ដូចជា "មនុស្សតែមួយ")

**DAVID** មិនផឹកគ្រឿងស្រវឹង មិនពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន ឬជក់ជាការកម្សាន្តទេ។ **DAVID** ពុំមានទំនងក្នុងរឿងស្នេហា ឬពាក់ព័ន្ធជាមួយនឹងពេស្យាចារទេ។ ចំណាប់អារម្មណ៍តែម្យ៉ាងគត់របស់ **DAVID** គឺការងាររបស់គាត់ ហើយជីវិតក្នុងសង្គមរបស់គាត់គឺទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងការងាររបស់គាត់។

រយៈពេលប្រហែល 7 ខែមុនថ្ងៃទី 14 ខែកុម្ភៈ ឆ្នាំ 2014 **DAVID** បានពាក់ព័ន្ធ និងរក្សាការជួបគ្នាជាមួយ **Andy (AL) Long** និង **Mao (MS) Salao** ទាក់ទងទៅនឹងការទទួលលុយវិនិយោគចំនួន USD 3,200,000 (បីលាន ពីររយពាន់ដុល្លារអាមេរិក) សម្រាប់ឧបត្ថម្ភដល់សំណើគម្រោងខ្សែភាពយន្តរបស់ **DAVID** និង **SONNY** គឺ "ANIMIST FARM"។
**SONNY** បានព្រមានម្តងហើយម្តងទៀត និងណែនាំយ៉ាងមុតមាំមិនឲ្យ **DAVID** មានការពាក់ព័ន្ធ ឬទាក់ទិនជាមួយនឹង **AL** និងរាល់អង្គភាពណាមួយដែលពាក់ព័ន្ធជាមួយនឹង **AL** ដោយសារសកម្មភាពខុសច្បាប់កាលពីអតីតកាល និងការសង្ស័យទៅលើសកម្មភាពខុសច្បាប់ក្នុងពេលបច្ចុប្បន្នរបស់ **AL** ។
ទោះជាយ៉ាងណា **DAVID** មើលស្រាលលើការបញ្ជាក់អះអាងរបស់ **SONNY** រាល់ការពាក់ព័ន្ធរបស់ **AL** នៅក្នុងការទំនាក់ទំនងទាំងនេះគឺ **MS** ដែល **DAVID** បានជួបជាមួយកាលពីមុន និងបានកសាងមិត្តភាពយ៉ាងជិតស្និទ្ធ និងជឿជាក់គ្នានៅប្រទេសកាណាដា។
**SONNY** បដិសេធមិនចូលរួមនៅក្នុងរាល់ការទំនាក់ទំនងជាមួយនឹង **AL**។ **SONNY** នៅតែរក្សាការព្រមានរបស់ខ្លួនអំពី **AL** ចំពោះ **DAVID** ទោះជាយ៉ាងណាជំនឿរបស់ **DAVID** ដែលមិត្តភក្តិគួរឲ្យជឿជាក់របស់គាត់គឺ **MS** មិត្តភក្តិរបស់ **MS** គឺ **AL** អាចផ្តល់ឲ្យវិនិយោគិនទាំងអស់ ឬដោយផ្អែកជាមួយនឹងលុយវិនិយោគដែលត្រូវការ ដែលជាលុយដែលគេមើលឃើញថាបានមកពីប្រភពស្របច្បាប់ ដែលមិនមែនបានមកពីសកម្មភាព ឬសហគ្រាសដែលមានបទឧក្រិដ្ឋសម្រាប់គម្រោងនេះទេ។
**DAVID** នៅតែចចេសរឹងរូសនៅក្នុងរបាយការណ៍របស់ខ្លួនទៅកាន់ **SONNY** ដែលថា លុយវិនិយោគសម្រាប់គម្រោងនេះ ត្រូវតែជាលុយស្របច្បាប់ ហើយនៅតែមានជំនឿក្នុងចិត្តថា **MS** និង **AL** កំពុងតែផ្តល់ជូនវិនិយោគិនស្របច្បាប់ជាមួយនឹងប្រាក់វិនិយោគស្របច្បាប់។

នៅម៉ោងប្រហែលជា 18:00 នៅថ្ងៃទី 12 ខែកុម្ភៈ ឆ្នាំ 2014 **DAVID** បានជួបជាមួយ **AL** និង **MS** នៅ 'បារ Karma' ផ្លូវសុខសាន្ត ដែលជាទីកន្លែងដែល **SONNY** ជឿជាក់ថា បញ្ហាលុយវិនិយោគមានការរីកចម្រើនទៅមុខទៀត។

នៅម៉ោងប្រហែលជា 17:00 ដល់ម៉ោង 18:00 នៅថ្ងៃទី 13 ខែកុម្ភៈ **DAVID** បានចូលរួមការប្រជុំនៅ 'បារ Karma'ម្តងទៀត។

ក្រោយមកទៀត មានដំណឹងពីទូរស័ព្ទចល័តរបស់ **DAVID** (Mobitel លេខ 012 877 307) ដោយ **SONNY** រៀបរាប់ថា នៅថ្ងៃទី 13 ខែកុម្ភៈ នៅម៉ោងប្រហែល 21:00 មានការហៅទូរស័ព្ទមកពី និងទៅកាន់ **AL**។

នៅអំឡុងពេលថ្ងៃនៃថ្ងៃទី 14 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** ចាប់ផ្តើមទូរស័ព្ទទៅកាន់ **DAVID** ដើម្បីបញ្ជាក់ថា គាត់ និង **DAVID** នឹងចូលរួមការប្រគុំតន្ត្រីមួយនៅ Thimomakia Temple តាមការគ្រោងទុកជាមុន ប៉ុន្តែរាល់ការហៅទូរស័ព្ទ និងក្រោយមកទៀតបានផ្ញើសារជាអក្សរនៅតែគ្មានការឆ្លើយតប។

នៅម៉ោងប្រហែល 20:00 នៅថ្ងៃទី 14 ខែកុម្ភៈ **SONNY** បានទៅកាន់ផ្ទះសំណាក់ Green Village Angkor ដើម្បីជួប **DAVID**។ នៅពេលគាត់បានមកដល់ គាត់បាននិយាយទៅកាន់បុរសវ័យក្មេងម្នាក់នៅកន្លែងទទួលភ្ញៀវ ដោយសួរថាបានឃើញ **DAVID** ដែរឬទេ និងបានឲ្យអ្នកទទួលភ្ញៀវជូនគាត់ទៅកាន់បន្ទប់របស់ **DAVID**។

នៅពេលចូលទៅក្នុងបន្ទប់របស់ **DAVID** លោក **SONNY** បានហៅឈ្មោះ **DAVID** ជាច្រើនដង ប៉ុន្តែពុំទទួលបានចម្លើយតបវិញទេ ដែលនៅពេលនោះ គាត់បានដើរកនៅក្នុងបន្ទប់ និងដើរទៅដល់បន្ទប់ទឹកដើម្បីរកមើល **DAVID**។

**DAVID** មិននៅក្នុងបន្ទប់នោះទេ តែទោះជាយ៉ាងណា **SONNY** បានសង្កេតឃើញទូរស័ព្ទចល័តរបស់ **DAVID** នៅជាប់នឹងឆ្នាំងសាកវានៅលើគ្រែ កុំព្យូទ័រម៉ាក់ MacBook របស់ **DAVID** ដែលកំពុងស្ថិតនៅក្នុង sleep mode មានខោអាវដែលទើបនឹងបោកគក់ហើយថ្មីៗ ដែល **SONNY** សន្មត់ទុកជាមុនថា **DAVID** បានទៅយកខោអាវមកពីហាងបោកអ៊ុតដែលមានទីតាំងនៅក្បែរផ្ទះសំណាក់នោះនៅថ្ងៃដដែលនោះ និងកាបូបរបស់ DAVID។ (ក្រោយមកទៀត លិខិតឆ្លងដែនរបស់ **DAVID** ត្រូវបានរកឃើញដោយ **SONNY** នៅក្នុងកាបូបនោះ។)

នៅត្រឹមពេលនេះ **SONNY** មានការព្រួយបារម្ភថាតើ **DAVID** នៅកន្លែងណា ពីព្រោះព្រឹត្តិការណ៍ និងកាលៈទេសៈកំពុងតែបង្ហាញថាស្ថិតនៅក្រៅបរិបទនៃទម្លាប់ក្នុងការប្រព្រឹត្តធម្មតារបស់ **DAVID** ហើយអ្វីដែលចម្លែកបំផុតនោះគឺ **DAVID** មិនឆ្លើយតបនឹងការទាក់ទងតាមទូរស័ព្ទជាមួយនឹង **SONNY**។

បន្ទាប់មកទៀត **SONNY** ចាប់ផ្តើមសួរអ្នកទទួលភ្ញៀវពាក់ព័ន្ធនឹងការបានឃើញ **DAVID** ដែរឬទេនៅថ្ងៃនោះ ដែលក្រោយមកទៀតគេបានប្រាប់ **SONNY** ថា នៅចន្លោះម៉ោង 11:00 ដល់ 12:00 **DAVID** បានចេញទៅញ៉ាំអាហារពេលព្រឹកនៅភោជនីយដ្ឋាន 'Five Sons' តាមទម្លាប់របស់គាត់ ហើយបន្ទាប់មកទៀតទៅយកខោអាវរបស់គាត់នៅហាងបោកអ៊ុត ប៉ុន្តែគាត់បានបាត់ទៅជាច្រើនម៉ោង ពីព្រោះ **SONNY** ជឿជាក់ថា **DAVID** ប្រហែលជាបានចំណាយពេលខ្លះបន្ថែមទៀតក្នុងការសន្ទនាគ្នាជាមួយស្ត្រីពិសេសម្នាក់ ដែលធ្វើការនៅហាងបោកអ៊ុតនោះ ដែលទោះបីជាស្ត្រីនោះជាជនជាតិខ្មែរក៏ដោយ តែនាងក៏ចេះនិយាយភាសាថៃ ដែលជាភាសាមួយដែល **DAVID** អាចសន្ទនាគ្នាជាមួយនាងបាន ហើយអនុញ្ញាតឲ្យគាត់ប្រើភាសានេះ រាល់ពេលជួបជាមួយនឹងស្ត្រីម្នាក់នេះ។

នៅម៉ោងប្រហែលចន្លោះពីម៉ោង 13:00 ដល់ម៉ោង 14:00 **DAVID** ត្រឡប់មកបន្ទប់របស់គាត់វិញ ហើយក្រោយមកទៀតមានការបញ្ជាក់ដោយអ្នកបោសសម្អាតថា នៅម៉ោងប្រហែល 14:00 DAVID បានចាកចេញពីបន្ទប់របស់គាត់ ដើម្បីឲ្យអ្នកបោសសម្អាតបានចូលទៅបោសសម្អាតបន្ទប់គាត់ ប៉ុន្តែមិនឃើញ **DAVID** ចេញពីផ្ទះសំណាក់ទេ **ចំណុចនេះគឺផ្ទុយគ្នាទៅនឹងការរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ ដែលថា **DAVID** បានទៅភោជនីយដ្ឋាន 'Five Sons' នៅម៉ោងប្រហែល 14:00**។

ថ្ងៃទី 15-កុម្ភៈ ម៉ោងប្រហែល 18.00, [initials]

ក្រោយមកទៀត ~~នៅម៉ោង 15:00~~ **SONNY** បានធ្វើការសាកសួរនៅភោជនីយដ្ឋាន 'Five Sons' ដែលជាកន្លែងដែលគាត់បានអះអាងនូវអ្វីដែលបានបញ្ជាក់ដោយអ្នកទទួលភ្ញៀវ។

សម្រាប់ពេលវេលាដែលនៅសេសសល់នៅក្នុងថ្ងៃនោះ **SONNY** នៅតែតាមរក **DAVID** នៅក្នុងទីផ្សា និងនៅកន្លែងដែល **DAVID** និង **SONNY** តែងតែទៅលេង ដោយសាកសួរអំពីកន្លែងដែល **DAVID** នៅ ពីអ្នកដែលពួកគេស្គាល់ ហើយត្រឡប់មកផ្ទះសំណាក់វិញជាច្រើនដង ដើម្បីបញ្ជាក់ឲ្យច្បាស់ថាតើ **DAVID** បានត្រឡប់មកវិញដែរឬទេ។ រាល់ការដើរស្វែងរក និងការសាកសួររបស់ **SONNY** បង្ហាញនូវចម្លើយអវិជ្ជមាន។

នៅថ្ងៃទី 15 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** នៅតែបន្តការស្វែងរក និងសាកសួរអំពីដំណឹងរបស់ **DAVID**។ **SONNY** ក៏បានទាមទារឲ្យផ្ទះសំណាក់ Green Village Angkor រាយការណ៍អំពីបញ្ហានោះជូនប៉ូលីសថាជាបញ្ហាបន្ទាន់ផងដែរ ប៉ុន្តែរាល់លើក គាត់ត្រូវបានគេប្រានចោល និងប្រាប់មកវិញថា "កុំព្រួយបារម្ភអី **DAVID** នឹងឃើញមកវិញទេ"។ (វាគឺជារឿងចាំបាច់ណាស់ ដែលផ្ទះសំណាក់នោះត្រូវរាយការណ៍ប្រាប់ប៉ូលីសអំពីមនុស្សដែលបាត់នោះ។)

នៅថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** មានការព្រួយបារម្ភយ៉ាងខ្លាំងអំពី **DAVID** ហើយក្រោយមកទៀតមានការក្តៅក្រហាយ និងខឹងសម្បារ ដោយសារតែការបដិសេធរបស់ផ្ទះសំណាក់ Green Village Angkor ក្នុងការរាយការណ៍ប្រាប់ប៉ូលីសអំពីបញ្ហានោះ ហើយបានប្រឈមមុខជាមួយនឹងអ្នកទទួលភ្ញៀវនៅផ្ទះសំណាក់នោះ ដោយនៅ ពេលនោះអ្នកទទួលភ្ញៀវបានជូន **SONNY** ទៅកាន់បន្ទប់របស់ **DAVID** ហើយអ្នកទទួលភ្ញៀវបានទទួលលិខិតឆ្លងដែនរបស់ **DAVID** ដែលក្រោយមកទៀត **SONNY** បានប្រាប់ឲ្យអ្នកទទួលភ្ញៀវរាយការណ៍ប្រាប់ប៉ូលីសអំពីមនុស្សដែលបាត់ខ្លួននោះជាផ្លូវការ។
អ្នកទទួលភ្ញៀវនោះ បានបដិសេធម្តងទៀត។
សម្រាប់រយៈពេលដែលនៅសេសសល់នៅក្នុងថ្ងៃនោះ **SONNY** ក៏នៅតែបន្តការស្វែងរក និងសាកសួរដំណឹងរបស់ **DAVID** ផងដែរ។

នៅថ្ងៃទី 17 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** បានទៅកាន់ផ្ទះសំណាក់ Green Village Angkor ដើម្បីបញ្ជាក់ឲ្យប្រាកដថាតើផ្ទះសំណាក់នោះបានបញ្ចប់ការធ្វើរបាយការណ៍អំពីមនុស្សបាត់ខ្លួនជាមួយប៉ូលីសហើយឬនៅ ហើយបានដឹងពីអ្នកទទួលភ្ញៀវនោះថាពុំមានការធ្វើរបាយការណ៍ណាមួយទេ ហើយបន្ទាប់មកទៀត **SONNY** បានឲ្យអ្នកទទួលភ្ញៀវជូន SONNY ទៅកាន់បន្ទប់របស់ **DAVID** ម្តងទៀត ហើយ **SONNY** ទទួលបានទូរស័ព្ទដៃរបស់ **DAVID** ហើយក្រោយមកទៀត **SONNY** បានទទួលលេខទូរស័ព្ទ

[signature]

ដែលរក្សាទុកនៅក្នុងទូរស័ព្ទដៃនោះ ហើយបានចាប់ផ្តើមហៅទូរស័ព្ទទៅកាន់លេខថ្មីៗទាំងអស់ដែលមានបង្ហាញ ដើម្បីទទូចនៅក្នុងការប្រឹងប្រែងតាមរក **DAVID**។ លេខដែលហៅច្រើនជាងគេបំផុតគឺលេខរបស់ **AL** និង **MS**។

SONNY បានធ្វើការសន្ទនាតាមទូរស័ព្ទជាច្រើនដងជាមួយ **MS (093 818 128)** ចាប់ពីថ្ងៃទី 17 ខែកុម្ភៈ ដែលអំឡុងពេលនោះ **MS** បានបញ្ជាក់អះអាងថា គាត់ពុំដឹងពីទីកន្លែងរបស់ **DAVID** ទេ ហើយពុំមានការចាប់អារម្មណ៍ក្នុងការពិភាក្សាអំពីបញ្ហាណាមួយដែលពាក់ព័ន្ធនឹង **DAVID** ឬការបាត់ខ្លួនរបស់ **DAVID** ឡើយ ដែលធ្វើឲ្យ **SONNY** មានការភ្ញាក់ផ្អើល ពីព្រោះ **MS** គួរតែជាមិត្តភក្តិស្លាប់រស់របស់ **DAVID** អស់រយៈជាង 30 (សាមសិប) ឆ្នាំកន្លងមកហើយ។ **DAVID** បានផ្តល់ការជឿទុកចិត្តទាំងស្រុងទៅលើ **MS** ហើយពុំមានការចូលរួមពាក់ព័ន្ធជាមួយនឹងការរៀបចំជាមួយ **SL (088 999 8181)** ឡើយ ហើយ **MS** ពុំមានការផ្តល់តម្លៃជឿទុកចិត្តច្រើនដូចដែល **MS** ឲ្យ **DAVID** ជឿជាក់ទៅលើ SL ដែរ។
វាគឺជារឿងគួរឲ្យចម្លែកមែនទែនដែលថា មិត្តភក្តិអស់មួយជីវិត **MS** ដែលមានការជឿទុកចិត្តគ្នាទាំងស្រុង បង្ហាញនូវការមិនចាប់អារម្មណ៍អំពីកន្លែងរស់នៅ និងសុខុមាលភាពរបស់មិត្តភក្តិគាត់ គឺ **DAVID** ឡើយ។

នៅថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** បានទៅកាន់ផ្ទះសំណាក់ Green Village Angkor ម្តងទៀត ដើម្បីបញ្ជាក់ឲ្យប្រាកដថា តើ ផ្ទះសំណាក់នោះបានបញ្ចប់ការធ្វើរបាយការណ៍អំពីមនុស្សដែលបាត់ខ្លួននោះជាមួយប៉ូលីសរួចហើយឬនៅ ហើយបានដឹងពីអ្នកទទួលភ្ញៀវនោះថា ពុំមានការធ្វើរបាយការណ៍ណាមួយទេ បន្ទាប់មកទៀត **SONNY** បានទៅកាន់ប៉ុស្តិ៍នគរបាលសង្កាត់សាលាកំដិក ដែលគាត់បានចាប់ផ្តើមធ្វើការរាយការណ៍ជាផ្លូវការអំពីមនុស្សដែលបាត់ខ្លួន ដែលនៅអំឡុងពេលនោះប៉ូលីសអន្តោប្រវេសន៍បានដឹង និងបន្ទាប់មកបានអមដំណើរជាមួយ SONNY ត្រឡប់ទៅកាន់ផ្ទះសំណាក់ Green Village Angkor ដែល **SONNY** យល់ថា ពួកគេបានចាប់ផ្តើមការសួរចម្លើយផ្លូវការ ដែលជាការឆ្លើយតបទៅនឹងការរាយការណ៍របស់ SONNY។
ទោះជាយ៉ាងណា បន្ទប់របស់ **DAVID** ពុំមានការបិទផ្លាក ឬសម្គាល់ជាផ្លូវការថាជាកន្លែងមានបទឧក្រិដ្ឋឡើយ ទោះបីជាយ៉ាងណានៅត្រឹមពេលនេះ SONNY ចាប់ផ្តើមជឿថា **DAVID** ប្រហែលជាត្រូវបានចាប់ពង្រត់ខណៈពេលកំពុងស្នាក់នៅផ្ទះសំណាក់ Green Village Angkor ហើយជាជនរងគ្រោះនៃល្បែងដ៏អាក្រក់នោះ។
មានច្រកចេញតាមផ្នែកខាងក្រោយនៃផ្ទះសំណាក់ ដែលជាផ្លូវនាំទៅកាន់កន្លែងស្នាក់នៅរបស់ម្ចាស់ផ្ទះសំណាក់ បន្ទាប់មកទៅតាមផ្លូវក្រោយ។
ដោយមិនទាក់ទងនឹងអ្វីដែលបានរៀបរាប់ពីខាងដើម **SONNY** ជឿជាក់ថា បញ្ហានេះពុំត្រូវបានពិភាក្សារកវិធីដោះស្រាយឲ្យបានម៉ត់ចត់ ហើយពុំទទួលបានការយកចិត្តទុកដាក់ពីប៉ូលីស ដែលជាអ្នកទទួលខុសត្រូវទេ។
សម្រាប់ពេលវេលាសេសសល់នៅក្នុងថ្ងៃនោះ **SONNY** ក៏នៅតែតាមរក និងសាកសួរដំណឹងរបស់ **DAVID** ដែរ។

នៅថ្ងៃទី 19 ខែកុម្ភៈ ការបាត់ខ្លួនរបស់ **DAVID** ត្រូវបានផ្សព្វផ្សាយជាសាធារណៈ តាមរយៈប្រភពប្រព័ន្ធផ្សព្វផ្សាយ ដោយផ្អែកទៅលើរបាយការណ៍អំពីមនុស្សបាត់ខ្លួន ដែល **SONNY** បានផ្តួចផ្តើមធ្វើ តែទោះជាយ៉ាងណាក្តី ការរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ និងការចេញផ្សាយព័ត៌មានរបស់ប៉ូលីសមានផ្ទុកទៅដោយព័ត៌មានជាច្រើន ដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៅជុំវិញការបាត់ខ្លួនរបស់ **DAVID** ហើយពុំបានរៀបរាប់អំពីការខិតខំប្រឹងប្រែងរបស់ **SONNY** ក្នុងការធ្វើឲ្យបញ្ហានេះមានការផ្សព្វផ្សាយឡើយ ហើយការងារដែល **SONNY** កំពុងធ្វើក្នុងការស្វែងរក **DAVID** និងសុំឲ្យអាជ្ញាធរដែលជាអ្នកអនុវត្តន៍ច្បាប់សមស្រប ប្រឈមទៅនឹង

បុគ្គលទាំងឡាយដែល **SONNY** ចោទប្រកាន់ថាអាចនឹងមានការពាក់ព័ន្ធជាមួយនឹងការសង្ស័យចាប់ពង្រត់ **DAVID** គឺមានឈ្មោះ **Andy (AL) Long** និង **Mao (MS) Salao** និងបុគ្គលទាំងឡាយដែលបានជួយដល់ជនដែលបានធ្វើខុស (ចារី) ដែលត្រូវបានចោទប្រកាន់នៅក្នុងបញ្ហានេះ។

ការរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាច្រើន បានបញ្ជាក់ដោយពុំត្រឹមត្រូវអំពី អចលនទ្រព្យដែលកំពុងស្ថិតក្រោមការអភិវឌ្ឍ ដែលជាកម្មសិទ្ធិរួមរបស់ **DAVID** និង **SONNY** ដែលមានចម្ងាយធ្វើដំណើរប្រហែល 2 ម៉ោង ចេញក្រៅក្រុងសៀមរាប ដែលគេចាត់ទុកថាជា "Animist Farm " ~~("កសិដ្ឋានវិញ្ញាណខ្មោច")។~~ [illegible]

អចលនទ្រព្យ 'Animist Farm" គឺជាផ្នែកដ៏តូចមួយនៃអចលនទ្រព្យដ៏ធំមួយដែលជាកម្មសិទ្ធិរបស់ដៃគូជីវិតរបស់ SONNY។ នាងបានផ្តល់អចលនទ្រព្យនោះទៅឲ្យ **DAVID** និង **SONNY** យោងទៅតាមកិច្ចសន្យាជួលរយៈពេល 30 ឆ្នាំ ដែលជួលក្នុងតម្លៃសរុប USD 3,000 (បីពាន់ដុល្លារអាមេរិក) សម្រាប់រយៈពេលនៃការជួលនោះ។

ឯកសារដែលផ្តល់ជូនដោយ **SONNY** និងមានភ្ជាប់មកជាមួយនេះ គឺជាច្បាប់ចម្លងឯកសារអំពី៖ ព័ត៌មានអំពីរបាយការណ៍ធនាគាររបស់អ្នកបង់ពន្ធ
ការផ្សព្វផ្សាយអំពីសាជីវកម្ម ដែលរៀបរាប់អំពីទ្រព្យសកម្មរបស់ **SONNY** និង **DAVID** និងកិច្ចសន្យាជួលទីតាំង Animist Farm។

បន្ទាប់ពី **SONNY** ទទួលបានទូរស័ព្ទរបស់ **DAVID** គាត់ក៏បានទាក់ទងបុគ្គលជាច្រើននៅកាណាដា ដើម្បីផ្សព្វផ្សាយអំពីអ្វីដែលគាត់បានដឹងពាក់ព័ន្ធនឹងបញ្ហានៃការបាត់ខ្លួនរបស់ **DAVID** ហើយរក្សាការផ្តល់ជំនួយនៅក្នុងការស្វែងរកទីកន្លែងរបស់ **DAVID**។

នៅថ្ងៃទី 22 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** បានចូលរួមនៅក្នុងការសម្ភាសន៍នៅស្នងការដ្ឋាននប៉ូលីសខេត្តសៀមរាប ដែលនៅពេលនោះគាត់ត្រូវបានគេសម្ភាសន៍ពាក់ព័ន្ធនឹងបញ្ហានៃការបាត់ខ្លួនរបស់ **DAVID**។ បន្ទាប់ពីសម្ភាសន៍រួច ប៉ូលីសអន្តោប្រវេសន៍ក៏បានចូលរួមផងដែរ។

នៅថ្ងៃទី 22 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** ត្រូវបានសម្ភាសន៍ដោយ **Allison Catmur** ជាលេខាទីពីរ (ថ្នាក់គ្រប់គ្រង) និងជារងកុងស៊ុល ដែលមកពីស្ថានទូតកាណាដា ប្រចាំនៅទីក្រុងបាងកក ប្រទេសថៃ ដែលពាក់ព័ន្ធនឹងបញ្ហានៃការបាត់ខ្លួនរបស់ **DAVID**។

នៅថ្ងៃទី 23 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** ផ្អែកលើព័ត៌មានដែលគាត់ទទួលបាន គាត់បានទៅជួបមន្ត្រីនគរបាលរដ្ឋបាលដែលមានឈ្មោះ '**ឆាត**' នៅភូមិជ្រាវ ដោយស្វែងរកទីកន្លែងរបស់ **MS** ដែលបានជូនដំណឹងដល់ **SONNY** ថា **MS** បានចេញពីភូមិនោះជាច្រើនម៉ោងមុនហើយ។ **ឆាត** បន្តបញ្ជាក់អះអាងទៀតថា គាត់មានការសង្ស័យយ៉ាងខ្លាំងទៅលើអាកប្បកិរិយារបស់ **MS** ដោយសារមូលហេតុជាច្រើន ទីមួយគឺដោយសារតែគាត់យល់ថា **MS** គឺជាជនបរទេសដែលមានលុយច្រើន ដែលកំពុងស្នាក់នៅក្នុងតំបន់ក្រីក្រមួយ ដោយពុំនៅជាមួយនរណាម្នាក់ ហើយនៅតែប្រកាន់ទម្លាប់រឹងរូស ហាក់ដូចជាគាត់កំពុងស្វែងរកការដោះសារមួយដូច្នោះដែរ។ បន្ទាប់មកទៀត **ឆាត** បានណែនាំឲ្យ **SONNY** ស្គាល់ម្ចាស់ផ្ទះដែល **MS** បានស្នាក់នៅ ហើយនៅពេលដែលត្រូវបានសួរថា

តើ អ្នកស្រីបានដឹងពីទីកន្លែងដែល MS បានទៅដែរឬទេនោះ អ្នកស្រីបានបញ្ជាក់ថា MS បានប្រាប់អ្នកស្រីថា លោកនឹងទៅភ្នំពេញដើម្បីទៅលេងប្អូនស្រីរបស់លោក។

នៅថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** បានជូនដំណឹងដល់ស្នងការប៉ូលីសខេត្តសៀមរាបអំពីការលទ្ធផលនៃការរកឃើញរបស់គាត់ ដែលពាក់ព័ន្ធនឹង **MS** មោះជាយ៉ាងណា នៅពេលត្រូវបានសួរថាតើ ប៉ូលីសនឹងទៅចាប់ខ្លួន **MS** ក្នុងពេលនោះដែរឬអត់នោះ ប៉ូលីសត្រូវតែដឹងថា **MS** គឺជាបុគ្គលដែលគួរឲ្យចាប់អារម្មណ៍នៅក្នុងបញ្ហានេះ ប៉ូលីសបានបញ្ជាក់ថា ពួកគេនឹងមិនទៅចាប់ខ្លួនទេ ដោយសារតែខ្វះកម្លាំង។

នៅរសៀលថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** បានធ្វើការសន្ទនាតាមទូរស័ព្ទជាមួយ **MS** ដែលអំឡុងពេលនោះ:

ដោយសារតែកង្វះការព្រួយបារម្ភដែល **MS** បានបង្ហាញឲ្យឃើញពាក់ព័ន្ធនឹង **DAVID** និងពាក់ព័ន្ធនឹងមិត្តភាពដែលគេបានដឹងរវាង **MS-DAVID** អស់រយៈពេលសាមសិបឆ្នាំ ដែល **MS** បានបង្ហាញឲ្យឃើញនូវការមិនយកចិត្តទុកដាក់ ដើម្បីសាកល្បងលើ **MS** បន្ថែមទៀត **SONNY** បានសួរ **MS** ថាតើ គាត់យល់ព្រមថាតើពួកគេគួរតែប្រកាសផ្សាយព័ត៌មានដោយផ្តល់ជារង្វាន់សម្រាប់ការផ្តល់ព័ត៌មានដែលនាំឲ្យរកឃើញទីកន្លែង និង/ឬសុខុមាលភាពរបស់ **DAVID** ដែរឬទេ ហើយ **MS** បានឆ្លើយតបមកវិញថា "អូខេ" ហើយគាត់នឹងត្រឡប់មកសៀមរាបវិញក្នុងកំឡុងពេលពីរឬបីថ្ងៃទៀត ដើម្បីជួយដល់ **SONNY** និងទោះជាយ៉ាងណា នៅពេល **SONNY** សួរអំពីទីកន្លែងរបស់ **MS** ថានៅឯណា **MS** បានបញ្ជាក់ថា គាត់នៅភ្នំពេញ ដោយកំពុងរៀបចំលិខិតឆ្លងដែនហើយជិតទៅកាណាដា។

នៅថ្ងៃទី 26 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** បានទទួលការហៅទូរស័ព្ទពី **MS** ដោយបញ្ជាក់ថា **MS** មិនសប្បាយចិត្តសោះ គាត់ត្រូវបានសម្ភាសន៍ដោយប៉ូលីស ពាក់ព័ន្ធនឹងការបាត់ខ្លួនរបស់ **DAVID** ហើយបានចាត់ទុកថា វាពុំសមរម្យទាល់តែសោះ ដែល **SONNY** បានផ្តល់ជូនប៉ូលីសជាមួយនឹង ព័ត៌មានលម្អិតរបស់ **MS**។

នៅថ្ងៃទី 28 ខែកុម្ភៈ ឆ្នាំ 2014 **SONNY** បានទទួលអ៊ីមែលមួយពី **Peter Vronsky** ដោយបានបញ្ជាក់ថា **Vronsky** បានចាត់តាំងអ្នកនាំពាក្យម្នាក់សម្រាប់គ្រួសាររបស់ **DAVID** និងបានផ្តល់ការផ្សព្វផ្សាយពាក់ព័ន្ធនឹង **MS** និងក្រុមគ្រួសាររបស់ **MS** ដែលកំពុងស្នាក់នៅក្នុងអចលនទ្រព្យដែល **DAVID** បានទិញកាលពីមុននៅតំបន់ Keswick នៃប្រទេសកាណាដា។ ឯកសារដែលភ្ជាប់មកជាមួយនេះ គឺជាអ៊ីមែលដែលផ្ញើមកពី **Vronsky**។

នៅត្រឹមពេលនេះ **SONNY** ដឹងថា គាត់ជាជនសង្ស័យសំខាន់ជាងគេចំពោះការបាត់ខ្លួនរបស់ **DAVID** ហើយឥឡូវនេះកំពុងស្ថិតក្រោមការពិនិត្យពិចារណាដោយសមាសភាពនៃប៉ូលីសអន្តោប្រវេសន៍។ **SONNY** ក៏បានដឹងយ៉ាងច្បាស់ថា ដៃគូរបស់គាត់ (ប្រពន្ធ) ក៏បានក្លាយជាជនសង្ស័យផងដែរ។

នៅថ្ងៃទី 1 ខែមីនា ឆ្នាំ 2014 **SONNY** បានទៅកាន់ស្នងការដ្ឋានប៉ូលីស ដែលនៅក្នុងអំឡុងពេលនោះ គាត់បានផ្តល់ទូរស័ព្ទរបស់ **DAVID** ទៅឲ្យមន្ត្រីប៉ូលីស ដែលក្រោយមកប៉ូលីសនោះបានផ្តល់ទូរស័ព្ទទៅខាងប៉ូលីសអន្តោប្រវេសន៍។

នៅថ្ងៃទី 3 ខែមីនា ឆ្នាំ 2014 **SONNY** បានទទួលអ៊ីមែលមួយទៀតពី Vronsky ដែលក្នុងនោះ Vronsky បែរជាស្តីបន្ទោស និងបានទាមទារសុំជំនួយពី **SONNY**។
ឯកសារដែលភ្ជាប់មកជាមួយនេះ គឺជាអ៊ីមែលដែលផ្ញើមកពី **Vronsky**។

នៅថ្ងៃទី 4 ខែមីនា ឆ្នាំ 2014 **SONNY** ទទួលបានដំណឹងពីប៉ូលីសអន្តោប្រវេសន៍ថា តំណាងអ្នកអនុវត្តន៍ច្បាប់កាណាដា កំពុងនៅសៀមរាប ដោយកំពុងទំនាក់ទំនងជាមួយផ្នែកអនុវត្តន៍ច្បាប់កម្ពុជា ពាក់ព័ន្ធនឹងបញ្ហានៃការបាត់ខ្លួនរបស់ **DAVID** តែទោះជាយ៉ាងណា **SONNY** នៅតែមានការភ្ញាក់ផ្អើលដែលថា មន្ត្រីអនុវត្តន៍ច្បាប់កាណាដា មិនស្នើឲ្យគាត់ផ្តល់បទសម្ភាសន៍។

នៅថ្ងៃទី 5 ខែមីនា ឆ្នាំ 2014 នៅម៉ោងប្រហែល 19:00 **SONNY** ស្រឡាំងកាំង ហើយក្រោយមកទៀតគាត់ខឹងយ៉ាងខ្លាំងដែលបានទទួលការហៅទូរស័ព្ទពីបុគ្គលម្នាក់ **ដែលបានបញ្ជាក់ថា** គេនោះគឺជាមេបញ្ជាការរងកងរាជអាវុធហត្ថ ខេត្តសៀមរាប ទទួលបន្ទុកមន្ទីរស្រាវជ្រាវ ឈ្មោះ **ស្រី យ៉ា** ( 015 888 837 ) ដោយត្អូញត្អែរថា គាត់កំពុងមានបញ្ហា និងលែងមានចំណូលចិត្តជាមួយ **AL** ពីព្រោះ **AL** ត្រូវបានសួរចម្លើយដោយមន្ត្រីប៉ូលីសសៀមរាប ពាក់ព័ន្ធនឹងការបាត់ខ្លួនរបស់ **DAVID** ហើយថា **ស្រី យ៉ា** បានឆ្លើយតបទៅនឹងចំណុចនេះមកពី **AL** ដោយបានបញ្ជាក់ទៅកាន់ **AL** ថា ប៉ូលីសគ្រាន់តែសួរចម្លើយ **AL** ដោយសារវាចាំបាច់ទៅតាមនីតិវិធីរបស់ប៉ូលីសតែប៉ុណ្ណោះ។
ចម្លើយតបរបស់ **SONNY** ចំពោះសំណួរនេះគឺ **SONNY** មិនមានទំនាក់ទំនងណាមួយជាមួយនឹងបញ្ហាដែលពាក់ព័ន្ធនឹងទំនាក់ទំនងរវាង **AL** និង **ស្រី យ៉ា** ទេ ហើយហេតុអ្វីបានជាគាត់ត្រូវគេជូនដំណឹងអំពីបញ្ហានេះ ដែលតាមពិតទៅគឺ **AL** ទេ ដែលជាអ្នកគួរត្រូវបានសួរចម្លើយពាក់ព័ន្ធនឹងការបាត់ខ្លួនរបស់ **DAVID** ព្រោះថា **AL** គួរតែជាជនសង្ស័យសំខាន់បំផុត ឬក៏ជាជនដែលត្រូវបានគេចាប់អារម្មណ៍តិចជាងគេ?
**SONNY** ពុំទទួលបានការឆ្លើយតបវិញទេ។

ផ្តល់ជាកសិណសាក្សីដោយ **SONNY CHHOUN**

នៅខេត្តសៀមរាប ប្រទេសកម្ពុជា នៅថ្ងៃទី 9 ខែមីនា ឆ្នាំ 2014